ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

រវាង

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
នៃក្រសួងសុខាភិបាល

និង

អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍

ស្តីពី

ការគាំទ្រដល់បណ្តាញសម្របសម្រួលការថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-ក្រុង
ចាប់ពីខែ តុលា ២០០៨ ដល់ កញ្ញា ២០០៩

ភ្នំពេញ កម្ពុជា
មករា ២០០៩

## ១. សេចក្តីផ្តើម

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា និងអង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ បានព្រមព្រៀងសហការ និងសម្របសម្រួលរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ដើម្បីពង្រឹងការលើកកំពស់សុខភាព និងការផ្តល់សេវាសុខភាព ជាពិសេសការថែទាំ និងបង្ការការឆ្លងរាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ និងកាមរោគ ។

អង្គការខាណា គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៅថ្ងៃទី ១១ មេសា ឆ្នាំ ២០០០ ។

អង្គការខាណា បានទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិសកលជុំទី៥ ដើម្បីបន្តការគាំទ្រដល់អ្នកសម្រប-សម្រួលការថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានី ចំនួន ១០ ដែលស្ថិតក្រោមការគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលក្នុងនោះរួមមាន រាជធានីភ្នំពេញ ខេត្តបាត់ដំបង កំពង់ចាម តាកែវ បន្ទាយមានជ័យ សៀមរាប កំពង់ធំ ពោធិសាត់ ព្រះសីហនុ និងព្រៃវែង ដោយគិតចាប់ពីខែតុលា ឆ្នាំ ២០០៨ ដល់ ខែកញ្ញា ឆាំ ២០០៩ ។

អង្គការខាណា នឹងធានាថា សកម្មភាព និងមូលនិធិដែលគាំទ្រដោយម្ចាស់ជំនួយរបស់ខ្លួន ត្រូវបានដាក់បញ្ចូលក្នុងផែនការ និងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់មន្ទីរសុខាភិបាលខេត្ត-រាជធានី និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។

គោលបំនង សកម្មភាព និងទីតាំង ដែលត្រូវធ្វើកិច្ចសហការរួមគ្នាចាប់ពីខែតុលា ២០០៨ ដល់ កញ្ញា ២០០៩ មានដូចខាងក្រោម :

## ២. គោលបំណង

- ដើម្បីរួមចំណែកជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងការផ្តល់ប្រាក់កំរៃបន្ថែមប្រចាំខែដល់មន្ត្រីរដ្ឋាភិបាលដែលបំរើការជាអ្នកសម្របសម្រួលការថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានី
- ដើម្បីធានាអោយមានការសម្របសម្រួល និងការអនុវត្តបានល្អលើសកម្មភាពនៃកម្មវិធីថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានី

- ដើម្បីលើកទឹកចិត្តមន្ត្រីដែលបំពេញការងារក្នុងការសម្របសម្រួលរាល់សកម្មភាពនៃកម្មវិធីថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានីទាំង១០។

## ៣. ទីតាំង និងតំបន់គោលដៅដែលត្រូវទទួលបានការគាំទ្រក្នុងកិច្ចសហប្រតិបត្តិការរវាង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការខាណា

អង្គការខាណា ប្តេជ្ញាចិត្តផ្តល់ការគាំទ្រទាំងផ្នែកគំរោងសកម្មភាព និងប្រាក់ឧបត្ថម្ភបន្ថែមប្រចាំខែដល់អ្នកសម្របសម្រួលបណ្តាញផ្នែកថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានីចំនួន ១០ រួមមាន រាជធានីភ្នំពេញ បាត់ដំបង កំពង់ចាម តាកែវ បន្ទាយមានជ័យ សៀមរាប កំពង់ធំ ពោធិសាត់ ព្រះសីហនុ និងខេត្តព្រៃវែង។

## ៤. ការទទួលខុសត្រូវរបស់ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការខាណា

**ភាគីទាំងពីរព្រមព្រៀងគ្នាតាមលក្ខខ័ណ្ឌដូចខាងក្រោម :**

1. KHANA បន្តគាំទ្រដល់បណ្តាញសម្របសម្រួលការថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានី (Provincial/Municipal CoC Coordination) ចំនួន ១០ ដែលស្ថិតក្រោម ការគាំទ្របច្ចេកទេសពី NCHADS ។ បណ្តាញសម្របសម្រួលការថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានី ទាំង ១០ នោះរួមមាន រាជធានីភ្នំពេញ ខេត្តបាត់ដំបង កំពង់ចាម សៀមរាប តាកែវ បន្ទាយមានជ័យ កំពង់ធំ ពោធិសាត់ ព្រះសីហនុ និងព្រៃវែង។
2. KHANA ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមប្រចាំខែចំនួន ១៦០ ដុល្លាអាមេរិក សំរាប់អ្នកសម្របសម្រួលការថែទាំ និងព្យាបាលបន្ត ថ្នាក់ខេត្ត-រាជធានី ដែលទទួលសម្របសម្រួលអនុវត្តគំរោងដែលគាំទ្រដោយ KHANA។ ប្រាក់ឧបត្ថម្ភនេះ គឺជាចំនួនថេរ ដោយមិនមានការតំឡើងប្រចាំឆ្នាំឡើយ។
3. ប្រាក់ឧបត្ថម្ភនេះ គឺជាផ្នែកមួយបន្ថែមទៅលើប្រាក់បៀវត្សរ៍របស់រដ្ឋាភិបាល សំរាប់ការចូលរួមអនុវត្តគំរោងសកម្មភាព និងការទទួលខុសត្រូវទាំងឡាយ ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង NCHADS និង KHANA ។

4. ភារកិច្ចទទួលខុសត្រូវរបស់អ្នកសម្របសម្រួលការថែទាំព្យាបាលបន្តខេត្ត-រាជធានី គឺមិនផ្តោតតែលើការថែទាំតាមផ្ទះដែលអង្គការខាណាគាំទ្រនេះទេ គឺត្រូវអនុលោមទាំងស្រុងតាមភារកិច្ចទទួលខុសត្រូវ ដែលកំនត់ដោយ NCHADS និងទទួលខុសត្រូវបន្ថែមលើ ការងារផែនការ ថវិកា ទិន្នន័យ និងរបាយការណ៍គំរោងដែលគាំទ្រដោយ KHANA ។
5. ការឧបត្ថម្ភទៅលើការចំណាយក្នុងការទំនាក់ទំនង និងការធ្វើដំណើរសំរាប់សកម្មភាពគំរោង អាចមានកំរិតខុសគ្នាទៅតាមស្ថានភាព និងទំហំនៃតំរូវការជាក់ស្តែងរបស់ខេត្ត-រាជធានីនីមួយៗ និងដោយអនុលោមតាមលទ្ធភាពជាក់ស្តែងរបស់អង្គការ KHANA ផងដែរ ។
6. ការចុះអភិបាលកិច្ចតាមស្រុកត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៨ ដុល្លា សំរាប់ថ្លៃអាហារក្នុងមួយថ្ងៃ និងបន្ថែម ៥ ដុល្លាសំរាប់ការស្នាក់នៅមួយយប់នៅតាមមូលដ្ឋាន។ ចំពោះការធ្វើដំណើរឆ្លងខេត្តត្រូវអនុលោមតាមគោលការណ៍របស់អង្គការ KHANA ។

## ៥. ប្រភពមូលនិធិ

ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលខេត្ត-រាជធានី និងអង្គការខាណា ក្នុងការជួយជ្រោមជ្រែងកិច្ចសម្របសម្រួល និងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែដល់អ្នកសម្របសម្រួលការថែទាំ និងព្យាបាលបន្តនៃខេត្ត-រាជធានីទាំង១០ អង្គការខាណា បានទទួលការគាំទ្រហិរញ្ញវត្ថុពីមូលនិធិសកលជុំទី៥ចំនួន **៧២,០២២.០០** (ប្រាំពីរម៉ឺនពីរពាន់ម្ភៃពីរ) ដុល្លាអាមេរិក។ មូលនិធិនេះនឹងគាំទ្រដល់បណ្តាញសម្របសម្រួលការថែទាំ និងព្យាបាលបន្តថ្នាក់ខេត្ត-រាជធានីនីមួយៗចំនួនប្រមាណ ៧,០០០.០០ (ប្រាំពីរពាន់) ដុល្លាអាមេរិក តាមកិច្ចព្រមព្រៀងនេះ ដែលត្រូវគិតចាប់ពី ខែតុលា ឆ្នាំ ២០០៨ ដល់ ខែកញ្ញា ២០០៩ ។

## ៦. បទប្បញ្ញត្តិទូទៅ

អង្គការខាណា នឹងផ្តល់គោលការណ៍ណែនាំក្នុងការកសាងផែនការ និងរបាយការណ៍ដល់អ្នកសម្រប-សម្រួលការថែទាំ និងព្យាបាលបន្តខេត្ត-រាជធានី ដោយអនុលោមតាមក្របខ័ណ្ឌផែនការប្រចាំឆ្នាំរបស់ NCHADS ។ ករណីមានការកែសំរួលខុសពីនេះ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយ NCHADS ។

## ៦. បទបញ្ញត្តិទូទៅ

អង្គការខាណា នឹងផ្តល់គោលការណ៍ណែនាំក្នុងការកសាងផែនការ និងរបាយការណ៍ដល់អ្នកសម្រប-សម្រួលការថែទាំ និងព្យាបាលបន្តខេត្ត-រាជធានី ដោយអនុលោមតាមក្របខ័ណ្ឌផែនការប្រចាំឆ្នាំរបស់ NCHADS ។ ការកែប្រែទាំងឡាយ នឹងត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយ NCHADS ។

អ្នកសម្របសម្រួលការថែទាំ និងព្យាបាលបន្តថាក់ខេត្ត-រាជធានី ត្រូវផ្តល់ផែនការ គំរោងថវិកា និងរបាយការណ៍ប្រចាំឆ្នាំមក NCHADS និង KHANA ។ លើសពីនេះត្រូវផ្តល់របាយការណ៍រីកចំរើន និងផែនការសកម្មភាពរៀងរាល់ត្រីមាសអោយបានទៀងទាត់មក NCHADS និង KHANA ។

នីតិវិធីទូទៅ ការសម្របសម្រួល ការធ្វើផែនការ និងការគ្រប់គ្រងគ្រប់សកម្មភាពដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តរួមគ្នាដោយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ/ក្រសួងសុខាភិបាល/មន្ទីរសុខាភិបាលខេត្ត-រាជធានី ក្នុងក្របខ័ណ្ឌការងាររបស់ NCHADS/MoH ស្តីពី "*ផែនការយុទ្ធសាស្ត្រសំរាប់ថែទាំ និងបង្ការមេរោគអេដស៍ និង ជំងឺអេដស៍ ឆ្នាំ ២០០៨-២០១០*" និងអនុលោមតាម *និយាមនៃបែបបទសំរាប់អនុវត្តសកម្មភាព* របស់មជ្ឈមណ្ឌល ជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អនុម័ត នៅខែ កុម្ភៈ ឆ្នាំ ២០០៦ ។

កិច្ចព្រមព្រៀងនេះមានសុពលភាពរយៈពេល១ឆ្នាំ ដោយគិតចាប់ពីខែតុលា ឆ្នាំ ២០០៨ ដល់ខែកញ្ញា ឆ្នាំ ២០០៩ ។

| | |
|---|---|
| **មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍** | **អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹង** |
| **សើស្បែក និងកាមរោគ** | **ជំងឺអេដស៍** |
| **ប្រធាន** | **នាយកប្រតិបត្តិ** |
| | KHANA<br>អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍<br>Khmer HIV/AIDS NGO Alliance |
| **ឯកឧត្តម វេជ្ជ. មាន ឈីវុន** | **វេជ្ជ. អ៊ុំ សុភាព** |